**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**សារលិខិត**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**ថ្លែងក្នុងឱកាសបើកបវេសនកាលឆ្នាំសិក្សា ២០១៨ - ២០១៩**

**ថ្ងៃ ព្រហស្បតិ៍ ៨ រោច ខែ អស្សុជ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២**

**ត្រូវនឹងថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៨**

*សូមថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ!*

*សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី!*

*សម្តេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា និង រាជរដ្ឋាភិបាល!*

*ឯកឧត្តម លោកជំទាវ ព្រឹទ្ធាចារ្យ លោកតា លោកយាយ!*

*លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្សជាទីស្រឡាញ់រាប់អាន និងបងប្អូនជនរួមជាតិទាំងអស់ ជាទីគោរពស្នេហា !*

ក្នុងឱកាសដ៏មហោឡារិកនៃបវេសនកាលឆ្នាំសិក្សាថ្មី ២០១៨-២០១៩ នេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមសម្តែងនូវក្តីសោមនស្សរីករាយ យ៉ាងក្រៃលែង និងសូមចូលរួមប្រកបដោយភាពស្និទ្ធស្នាលជាមួយបងប្អូនជនរួមជាតិ ស្របពេល ដែលឆ្នាំ ២០១៨ ជាខួបទី ២០ នៃការបង្រួបបង្រួមជាតិ ការរក្សាបានសន្តិភាពពេញលេញជូនប្រទេសជាតិ និងការអភិវឌ្ឍលើគ្រប់វិស័យ។

ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៨ នេះ ជាថ្ងៃដ៏មានអត្ថន័យយ៉ាងជ្រាលជ្រៅបំផុតរបស់ក្មួយៗ ជាសិស្សានុសិស្សចំណោះទូទៅទាំងអស់ ដែលជាកុលបុត្រ កុលធីតាជាទីស្រឡាញ់របស់យើងគ្រប់ៗគ្នា មានឱកាសទទួលបាននូវការអប់រំ ឱកាសក្នុងការបន្តការសិក្សារៀនសូត្រ និងជាថ្ងៃចាប់ផ្តើមនៃជីវិតសិក្សាដំបូងរបស់កុមារតូចៗ ដែលទើបនឹងដល់អាយុត្រូវចូលសាលារៀន។

នាពេលកន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានវិនិយោគយ៉ាងសន្ធឹកសន្ធាប់លើវិស័យអប់រំ ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធអប់រំនៅទូទាំងប្រទេស ការយកចិត្តទុកដាក់ដល់សិស្សជួបការលំបាក ការលើកកម្ពស់លក្ខខណ្ឌការងារ និងលក្ខខណ្ឌរស់នៅរបស់គ្រូបង្រៀនជាបន្តបន្ទាប់ ។ ឆ្លៀតក្នុងឱកាសនេះ តាងនាមរាជរដ្ឋាភិបាលកម្ពុជានិងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះលោកគ្រូ អ្នកគ្រូបង្រៀនទាំងអស់នៅទូទាំងប្រទេស ដែលបានខិតខំលះបង់កម្លាំងកាយ ប្រាជ្ញា ស្មារតី បង្ហាត់បង្រៀនសិស្សឱ្យទទួលបានចំណេះដឹង ជំនាញ សីលធម៌ និងកាយសម្បទារឹងមាំ ដើម្បីក្លាយជាពលរដ្ឋល្អ ដែលជាសសរទ្រូងដ៏រឹងមាំក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យសំបូររុងរឿង ជាមួយគ្នានេះការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាលសិស្ស អាជ្ញាធរដែនដី និងដៃគូអភិវឌ្ឍទាំងអស់ ក៏ជាកម្លាំងសរុបមួយជួយដល់ការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជាឱ្យមានដំណើរការយ៉ាងលូន និងទទួលបានជោគជ័យគួរជាទីមោទនៈក្នុងរយៈពេលកន្លងមកនេះ ។

*ជនរួមជាតិជាទីស្នេហា!*

ក្នុងអាណត្តិទី ៦ នេះ ខ្ញុំព្រះករុណាខ្ញុំបានដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ដោយបានចាត់ទុកការអភិវឌ្ឍធនធានមនុស្ស ជាអាទិភាពទី ១ និងប្តេជ្ញាសម្រេចឱ្យបាននូវមុំទី ១ ស្តីពី "ការពង្រឹងគុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា" ស្របពេលជាមួយគ្នាដែលការអប់រំនៅកម្ពុជា បានធ្វើមូលដ្ឋានីយកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ស្តីពីការអប់រំឆ្នាំ ២០៣០ ឆ្ពោះទៅធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

ក្នុងយុគសម័យ សេដ្ឋកិច្ចពុទ្ធិ និង បច្ចេកវិទ្យាព័ត៌មាន នាពេលបច្ចុប្បន្ននិងទៅអនាគត ធនធានមនុស្សដែលមានចំណេះដឹង ចំណេះធ្វើទូលំទូលាយ មានភាពច្នៃប្រឌិតខ្ពស់ និងមានជំនាញច្បាស់លាស់ កាន់តែមានសារៈសំខាន់ក្នុងការបង្កើនឧត្តមភាពប្រកួតប្រជែងរបស់ប្រទេសជាតិ ជាពិសេសក្នុងស្ថានភាពដែលកម្ពុជាត្រូវប្រឹងរស់ ងើបឈរឡើង ដើម្បីការពារឯករាជ្យ អធិបតេយ្យ និងសន្តិភាពរបស់ប្រទេស ។ ព្រះរាជាណាចក្រកម្ពុជាមានចក្ខុវិស័យច្បាស់លាស់ក្នុងការបណ្តុះបណ្តាលមូលធនមនុស្ស ឆ្ពោះទៅកាន់សង្គមពុទ្ធិ និងវិបុលភាព ដែលប្រជាពលរដ្ឋមានចំណេះដឹង មានវប្បធម៌ជ្រៅជ្រះ មានផលិតភាព និងមានភាពប្រកួតប្រជែងខ្ពស់ ឆ្លើយតបយ៉ាងសមស្របនិងទាន់ពេលវេលា ទៅនឹងគោលនយោបាយអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសការប្រែក្លាយពីប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ ២០៣០ និងក្លាយទៅជាប្រទេសមានប្រាក់ចំណូលខ្ពស់នាឆ្នាំ ២០៥០ ។

ក្នុងស្មារតីនេះ ដើម្បីធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំសូមអំពាវនាវដូចតទៅ ៖

ទី១- ក្រសួងអប់រំយុវជន និងកីឡា និងស្ថាប័នពាក់ព័ន្ធត្រូវពិនិត្យឡើងវិញគោលនយោបាយ ក្របខណ្ឌច្បាប់ បទដ្ឋាន និងយន្តការចាំបាច់ ដើម្បីដឹកនាំ គ្រប់គ្រង និងអនុវត្តឱ្យមានប្រសិទ្ធភាពនិងធានាបាននូវលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្នសម្រាប់សិស្សានុសិស្សគ្រប់រូប និងស្របទៅនៅបរិការណ៍ថ្មីនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ។

ទី ២- គ្រឹះស្ថានសិក្សាគ្រប់រូបភាព រួមទាំងទីវត្តអារាម ត្រូវធានាលទ្ធភាពក្នុងផ្តល់ការអប់រំពេញលេញ និងមានគុណភាព ដោយត្រូវបង្កើនការផ្សព្វផ្សាយនិងធ្វើយុទ្ធនាការប្រមូលកុមារចូលរៀន រៀបចំនិងជួសជុលបន្ទប់រៀន សង្ហារិម តុ កៅអី ក្តារខៀន ទ្វារ បង្អួច បង្គន់អនាម័យ កន្លែងលាងសម្អាតដៃ និងបរិក្ខារនានា ដើម្បីធានាថា សាលារៀនមានបរិស្ថានសិក្សាស្អាត អនាម័យប្រកបដោយនិរន្តរភាព និងផាសុកភាព ។ សាលារៀនត្រូវត្រៀមលក្ខណៈតាមគ្រប់រូបភាព ក្នុងករណីមានប្រធានស័ក្តិ ដូចជាអាកាសធាតុក្តៅហួតហែង ទឹកជំនន់ ខ្យល់កន្ត្រាក់ ។ ល ។ សាលារៀនទាំងអស់ត្រូវធានារយៈពេលនៃការរៀននិងបង្រៀនបានពេញលេញ ស្របតាមកម្មវិធីសិក្សាដែលបានកំណត់ ។ ចំពោះសាលារៀនដែលមានអនុវត្តកម្មវិធីនានា ត្រូវខិតខំបង្កើនប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធក្នុងការអនុវត្ត ដូចជាការផ្តល់អាហារូបករណ៍ដល់សិស្សជួបការលំបាក ការផ្តល់អាហារពេលព្រឹកឬអាហារថ្ងៃត្រង់ ។ ល ។

ទី ៣- លោកគ្រូ អ្នកគ្រូទាំងអស់ត្រូវខិតខំប្រឹងប្រែងអភិវឌ្ឍសមត្ថភាពខ្លួនបន្ថែមទៀត ទាំងផ្នែកចំណេះដឹងនិងវិធីសាស្ត្របង្រៀន រួមទាំងបច្ចេកវិទ្យាព័ត៌មាន ភាសាបរទេស ដើម្បីយកចំណេះដឹងថ្មីៗ មកបង្ហាត់បង្រៀនសិស្សបន្តទៀត ។

ទី ៤- ក្មួយៗជាសិស្សានុសិស្ស និងយុវជន យុវនារីទាំងអស់ត្រូវខិតខំរៀនសូត្រឱ្យខ្ជាប់ខ្ជួន ព្រមទាំងចូលរួមគ្រប់សកម្មភាពនានា ដើម្បីគាំទ្រដំណើរការអភិវឌ្ឍសាលារៀន និងសង្គមជាតិរបស់យើង ។ ជាងនេះទៀត ក្មួយៗសិស្សានុសិស្សទាំងអស់ត្រូវចងចាំថា បើយើងស្រឡាញ់ខ្លួនយើង ស្រឡាញ់ឪពុកម្តាយ និងស្រឡាញ់អនាគតរុងរឿង ក្មួយៗត្រូវនៅឱ្យឆ្ងាយពីគ្រឿងញៀន អំពើអបាយមុខផ្សេងៗ និងអំពើអសកម្មនានា ។

ទី ៥- មាតាបិតា អ្នកអាណាព្យាបាលសិស្ស និងសហគមន៍ត្រូវរួមចំណែកឱ្យបានខ្លាំងក្លាថែមទៀត ប្រកបដោយនិរន្តភាព ក្នុងការជួយអប់រំកូនចៅ ទាំងផ្នែកសុខភាព ចំណេះដឹង និងសីលធម៌ ។

ទី ៦- អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវយកចិត្តទុកដាក់ចូលរួមគាំទ្រឱ្យបានខ្លាំងក្លាបន្ថែមទៀត ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការគាំទ្រផ្សេងៗទៀតតាមគ្រប់លទ្ធភាព ព្រមទាំងជំរុញសិស្ស និងយុវជនដែលមិនបានរៀនសូត្រឬបោះបង់ការសិក្សាឱ្យមានឱកាសទទួលបានការរៀនសូត្រជាថ្មី ជាពិសេសត្រូវខិតខំបង្កលក្ខណៈងាយស្រួលដល់សិស្ស និងយុវជន ដែលមានពិការភាពឱ្យទទួលបានលទ្ធភាពក្នុងការសិក្សារៀនសូត្រ ។

ទី ៧- ប្រព័ន្ធផ្សព្វផ្សាយទាំងអស់រួមមាន វិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្តី ព្រឹត្តិបត្រព័ត៌មានរបស់រដ្ឋនិងឯកជន សូមជួយផ្សព្វផ្សាយនិងបញ្ជ្រាបឱ្យបានកាន់តែទូលំទូលាយ អំពីសារៈសំខាន់នៃការអប់រំ ព្រមទាំងអំពាវនាវដល់មាតាបិតា ឬអាណាព្យាបាលសិស្សឱ្យនាំកូនដល់អាយុមកចុះឈ្មោះចូលរៀនបានគ្រប់ៗគ្នា ។

ទី ៨- ដៃគូអភិវឌ្ឍនិងអង្គការមិនមែនរដ្ឋាភិបាលត្រូវបង្កើនកិច្ចសហការនិងពង្រឹងភាពជាដៃគូកាន់តែខ្លាំងថែមទៀត ក្នុងការជួយឧបត្ថម្ភគាំទ្រដល់កម្មវិធីអប់រំនានា ជាពិសេសនៅកន្លែងដែលសេវាអប់រំពិបាកទៅដល់ឬក្រុមសិស្សជួបការលំបាក ។

ជាថ្មីម្តងទៀត ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំសូមថ្លែងអំណរគុណដល់គ្រប់ក្រសួង ស្ថាប័ន អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ សប្បុរសជននានា ព្រះសង្ឃ ចាស់ព្រឹទ្ធាចារ្យ បព្វជិតសាសនា និងប្រជាពលរដ្ឋទាំងអស់ ដែលបាននិងកំពុងជួយឧបត្ថម្ភគាំទ្រយ៉ាងសកម្មដល់ការងារអប់រំនាពេលកន្លងមក ។ ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំសង្ឃឹមថា បវេសនកាលឆ្នាំសិក្សា ២០១៨- ២០១៩ នឹងបន្តដាស់ស្មារតីយើងទាំងអស់គ្នាឱ្យចូលរួមលើកកម្ពស់ការអប់រំនៅកម្ពុជាកាន់តែសកម្ម និងរស់រវើកថែមទៀត ។

ជាទីបញ្ចប់ ទូលព្រះបង្គំជាខ្ញុំព្រះករុណាខ្ញុំ សូមថ្វាយព្រះពរ និងប្រគេនពរសម្តេចព្រះសង្ឃរាជ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងជូនពរបងប្អូនជនរួមជាតិ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំ ព្រមទាំងក្មួយៗជាទីស្រឡាញ់ទាំងអស់ សូមសមប្រកបដោយពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃព្រហស្បតិ៍ ៨ រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**